01623288

F47

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Jul-2019, 08:30
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ត.ក៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

## សំណើបន្ទាន់លើកទីមួយរបស់លោក នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ដាក់សារណាលើបណ្ដឹងសាទុក្ខជំទាស់នៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្ដី នួន ជា៖**
សុន អរុណ
លីវ សុវណ្ណា
Doreen CHEN
ព្រំ ផល្លា
Xiaoyang NIE
Marina HAKKOU
ឌី សុជាតា
Gaëlle BUCHET
Stephanie ERIAN
Khady BÂ

**ដាក់ជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande-MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**
ជា លាង
Brenda J. HOLLIS (បម្រុង)

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**
ពេជ អង្គ

**ក្រុមមេធាវីការពារក្ដី ខៀវ សំផន៖**
គង់ សំអុន
Anta GUISSÉ

## ផ្នែកទី ១. សេចក្តីផ្តើម

១. អនុលោមតាមវិធាន ៣៩ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង") និង មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារ សហមេធាវីការពារក្តីរបស់ នួន ជា ("មេធាវីការពារក្តី") ស្នើសុំដូចខាងក្រោម៖

(ក) បន្ថែមពេលវេលា ៨,៥ ខែ ទៅលើពេលវេលាកំណត់ ៦០ ថ្ងៃ ក្នុងការដាក់សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២ ដោយពេលវេលាសរុបទាំងអស់មានចំនួន **១០,៥ ខែ** វិញ គិតចាប់ពីថ្ងៃដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ នួន ជា។

(ខ) បន្ថែមចំនួន ៩៧០ ទំព័រ ទៅលើចំនួនកំណត់ ៣០ ទំព័រ សម្រាប់សារណាបណ្តឹងសាទុក្ខ ដោយមានចំនួនសរុប **១.០០០** ទំព័រ ជាភាសាអង់គ្លេស។ និង

(គ) ដាក់សារណាបណ្តឹងសាទុក្ខរបស់ នួន ជា ជាភាសាអង់គ្លេសជាមុនសិនត្រឹមថ្ងៃកំណត់ចុងក្រោយនោះ ចំណែកសំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយនៅពេលបញ្ចប់ការបកប្រែភ្លាម

(តទៅនេះហៅថា "សំណើ")។

## ផ្នែកទី២. សាវតារ

២. នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសជាផ្លូវការនូវសេចក្តីសង្ខេបសាលក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០២ ទៅលើ នួន ជា និង ខៀវ សំផន[1]។

៣. នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ លោកស្រី Doreen Chen ត្រូវបានចាត់តាំងជាសហមេធាវីអន្តរជាតិថ្មីសម្រាប់ការពារក្តីលោក នួន ជា[2]។ បន្ទាប់មកសហមេធាវីការពារក្តីបានពន្លឿន

---

[1] "សាលក្រមសង្ខេបរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ("សាលក្រមសង្ខេប")។

ដំណើរការជ្រើសរើសបុគ្គលិកសម្រាប់ក្រុមថ្មី។ នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ អ្នកវិភាគភស្តុតាងជាន់ខ្ពស់ត្រូវបានចាត់តាំងជាថ្មីឡើងវិញ និងមន្ត្រីពិគ្រោះយោបល់ចំនួន ៦ នាក់ ដែលធ្វើការពេញម៉ោង និង មិនពេញម៉ោង ត្រូវបានតែងតាំងសម្រាប់ជំនួយការផ្នែកច្បាប់របស់ក្រុមមេធាវីការពារក្តី។

៤. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមជាលាយលក្ខណ៍អក្សរ មានសំអាងហេតុពេញលេញទៅលើរូប នួន ជា និង ខៀវ សំផន ("សាលក្រម")[3]។ ដោយសារភាគីទទួលការជូនដំណឹងពីសាលក្រមនៅម៉ោង ៨:៣៧ យប់ ដែលហួសម៉ោងការងារ អង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") ចាត់ទុកថា សាលក្រមត្រូវបានជូនដំណឹងនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩[4] វិញ។

៥. នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ មេធាវីការពារក្តីបានស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងរបស់ខ្លួនអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម[5]។ មេធាវីការពារក៏បានបង្ហាញផងដែរថា ខ្លួននឹងដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់

---

[2] ឯកសារ **E464** "ការចាត់តាំងសហមេធាវីបរទេសថ្មី តំណាងឲ្យលោក នួន ជា នៅក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។

[3] ឯកសារ **E465** "សាលក្រមសំណុំរឿង ០០២/០២" ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ [*sic* ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩] ("សាលក្រម")។

[4] ឯកសារ **F43** "សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ" ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ("សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២") កថាខណ្ឌ ១២។

[5] ឯកសារ **F40/1.1** "សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំចំនួនទំព័រ និងពេលវេលាបន្ថែម សម្រាប់ការដាក់ជូនសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ ("សំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាដើម្បីដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខរបស់គាត់")។

ដើម្បីដាក់សារណាបណ្តឹងសាទុក្ខ នៅពេលខ្លួនទទួលការអនុញ្ញាតឲ្យដាក់សំណើនេះបាន[6]។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ អង្គជំនុំជម្រះបានទទួលយកផ្នែកខ្លះនៃសំណើរបស់មេធាវីការពារក្តី ដោយអនុញ្ញាតឲ្យបន្ថែមពេលវេលាចំនួន ៦០ ថ្ងៃ និងបន្ថែមចំនួន ៣០ ទំព័រ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[7]។

៦. នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងរបស់ខ្លួនអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម (“សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ” ឬ “សេចក្តីជូនដំណឹង”) ដោយលើកឡើងមូលដ្ឋានចំនួន ៣៥១ និងមូលដ្ឋានរងចំនួន ១៩២ នៃបណ្តឹងសាទុក្ខចំពោះកំហុសសរុបចំនួន ៥៤៣[8]។ នៅថ្ងៃដដែលនោះ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សេចក្តីជូនដំណឹងរបស់ខ្លួនអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ដែលបង្ហាញនូវកំហុសចំនួន ១.៨២៤ និងសេចក្តីសម្រេចបន្ទាន់បង្ខំចំនួន ៣៥៥ ដែលអាចប្តឹងសាទុក្ខបាន[9]។

៧. នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើសុំបន្ថែមទំព័រចំនួន ៩២០ ទំព័រ និងពេលវេលាបន្ថែមចំនួន ៨,៥ ខែ ទៅលើចំនួនកំណត់សម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខដែលមានទំព័រសរុបចំនួន ៩៥០ ទំព័រ និងរយៈពេលសរុប ១០,៥ ខែ សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ[10]។

## ផ្នែកទី៣. ច្បាប់ជាធរមាន

---

[6] ឯកសារ **F40/1.1** សំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាដើម្បីដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខរបស់គាត់ កថាខណ្ឌ ៦០។

[7] ឯកសារ **F43** សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១៣។

[8] ឯកសារ **E465/3/1** “សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២” ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ (“សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ”)។

[9] ឯកសារ **E465/4/1** “សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន (សំណុំរឿង ០០២/០២)” ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ កថាខណ្ឌ ១៥។

[10] ឯកសារ **F45** “សំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រនៃសារណាបណ្តឹងសាទុក្ខ” ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩។

៨. មាត្រា ៣៣ *ថ្មី* នៃច្បាប់បង្កើត អ.វ.ត.ក ធានាដល់បុគ្គលម្នាក់ៗនូវសិទ្ធិទទួលបានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន ដោយឆ្លុះបញ្ចាំងជាពិសេស ទៅនឹង មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[11]។

៩. វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុងចែងថា "ភាគីដែលមានបំណងប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចណាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ដោយបញ្ជាក់ពីមូលដ្ឋាននៃបណ្តឹងសាទុក្ខនោះ។ [...] បន្ទាប់មកម្ចាស់បណ្តឹងសាទុក្ខ ត្រូវដាក់សារណាបណ្តឹងសាទុក្ខដោយបញ្ជាក់ពីទឡ្ហីករណ៍ និងឯកសារសំអាងផ្លូវច្បាប់ដែលគាំទ្រមូលដ្ឋាននីមួយៗ"។ អនុលោមតាមវិធាន ១០៧(៤) "ម្ចាស់បណ្តឹងសាទុក្ខត្រូវដាក់ជូនសារណាបណ្តឹងសាទុក្ខក្នុងរយៈពេល ៦០ ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងពីការប្តឹងសាទុក្ខ"។ ក្រៅពីនេះ មាត្រា ៣៩(៤) នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាច "តាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ ឬ តាមគំនិតផ្តួចផ្តើមរបស់ខ្លួន [...] ពន្យារពេលវេលាកំណត់ ដែលខ្លួនបានកំណត់"។

១០. មាត្រា ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារចែងថា៖ ឯកសារដាក់នៅអង្គបុរេជំនុំជម្រះ ឬ អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក មិនត្រូវលើសពី ៣០ ទំព័រ ជាភាសាអង់គ្លេស ឬភាសាបារាំង។ មាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តចែងបន្ថែមថា "អង្គជំនុំជម្រះដែលពាក់ព័ន្ធ អាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស"។

---

[11] មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប្រើប្រាស់ពាក្យពេចន៍ដូចគ្នាបេះបិទថា៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរិមា និងស្មើៗគ្នាសមស្របតាមមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ [...] ខ) មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន ដែលជ្រើសដោយខ្លួនឯង"។ ការការពារដោយការជំនុំជម្រះដោយយុត្តិធម៌នៅក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏ត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងច្បាប់កម្ពុជាដែរ តាមរយៈមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

១១. នៅក្នុងការកំណត់ថា តើមានមូលហេតុសមស្របក្នុងការផ្លាស់ប្តូរនូវការកំណត់នីតិវិធី ឬយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូល (“អង្គជំនុំជម្រះ”) បានពិចារណានូវកត្តាដូចខាងក្រោម៖ (១) ទំហំ និង ភាពស្មុគ្រស្មាញនៃសំណុំរឿង[12] (២) បញ្ហាថ្មីៗ ដែលត្រូវពិនិត្យ[13] និង (៣) ការចាត់តាំងមេធាវីថ្មី[14] និង (៤) ឥទ្ធិពលនៃវ័យចាស់ជរា និងបញ្ហាសុខភាពរបស់ជនជាប់ចោទទៅលើលទ្ធភាពរបស់មេធាវីការពារក្តី ក្នុងការទទួលការណែនាំយ៉ាងមានប្រសិទ្ធភាព[15]។

១២. ដូចគ្នានេះដែរ អង្គជំនុំជម្រះនៅក្នុងតុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី (“ICTY”) តុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (“SCSL”) បានទទួលស្គាល់ថា ចំនួនសន្លឹកនៃសាលក្រម[16] ទំហំនៃកំណត់

---

[12] *សំណុំរឿង ០០១* ឯកសារ **F6/2** “សេចក្តីសម្រេចលើសំណើសហមេធាវីការពារក្តីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច សុំពេលវេលាបន្ថែមសម្រាប់ដាក់បណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង” ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ (“សេចក្តីសម្រេចលើពេលវេលាបន្ថែមដើម្បីដាក់ជូនបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១”) កថាខណ្ឌ ៨ និង ១០ និង ឯកសារ **F43** សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៨។

[13] *សំណុំរឿង ០០១* ឯកសារ **F6/2** “សេចក្តីសម្រេចលើសំណើសហមេធាវីការពារក្តីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច សុំពេលវេលាបន្ថែមសម្រាប់ដាក់បណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង” ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៨ និង ១០ និង ឯកសារ **F43** សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៨។

[14] **F6/2** “សេចក្តីសម្រេចលើសំណើសហមេធាវីការពារក្តីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច សុំពេលវេលាបន្ថែមសម្រាប់ដាក់បណ្តឹងសាទុក្ខជំទាស់នឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង” ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ (“សេចក្តីសម្រេចលើពេលវេលាបន្ថែមដើម្បីដាក់ជូនបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១” កថាខណ្ឌ ៨ និង ១០។

[15] ឯកសារ **F43** សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៩។

[16] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-2946 “សេចក្តីសម្រេចលើសំណើរបស់លោក Lubanga សុំបន្ថែមចំនួនទំព័រកំណត់” ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១២ (“សេចក្តីសម្រេចលើការបន្ថែមចំនួនទំព័រកំណត់ក្នុង*រឿងក្តី Lubanga*”) កថាខណ្ឌ ៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Katanga* សំណុំរឿងលេខ ICC-01/04-01/07-3454 “សេចក្តីសម្រេចលើសំណើរបស់លោក Germain Katanga និងរដ្ឋអាជ្ញាទាក់ទិននឹងពេលវេលាកំណត់សម្រាប់ដាក់បណ្តឹងឧទ្ធរណ៍” ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ (“សេចក្តីសម្រេចលើការបន្ថែមចំនួនទំព័រកំណត់ក្នុង*រឿងក្តី Katanga*”)

ហេតុសំណុំរឿង[17] ភាពស្មុគ្រស្មាញ និង ការពិនិត្យលើបញ្ហាថ្មីៗ[18] វិសាលភាពនៃបណ្តឹងសាទុក្ខ[19] អង្គហេតុដែលថា ការផ្តន្ទាទោសស្ថិតក្រោមបណ្តឹងសាទុក្ខពាក់ព័ន្ធនឹងអំពើព្រហ្ម

---

កថាខណ្ឌ ១៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Šainović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-87-A "សេចក្តីសម្រេចលើញត្តិរួមរបស់ Nikola Šainović និង Dragoljub Odjanić សុំបន្ថែមចំនួនអក្សរកំណត់" ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩ ("សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង*រឿងក្តី Šainović*") ទំព័រ ៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Prlić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-74-A "សេចក្តីសម្រេចលើសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំបន្ថែមពេលវេលា និងចំនួនអក្សរកំណត់") ទំព័រ ៤ ("សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរ និងពេលវេលាក្នុង*រឿងក្តី Prlić*") ទំព័រ ៤។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A "សេចក្តីសម្រេចលើញត្តិស្នើសុំបន្ថែមចំនួនអក្សរកំណត់" ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង*រឿងក្តី Karadžić*") ទំព័រ ២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿងលេខ MICT-13-55-A "សេចក្តីសម្រេចលើញត្តិរួមស្នើសុំការបន្ថែមពេលវេលាដាក់បណ្តឹងឧទ្ធរណ៍ និងសារណាតប" ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង*រឿងក្តី Karadžić*") ទំព័រ ២ និង *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Taylor* សំណុំរឿងលេខ SCSL-03-01-A "សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា និងមេធាវីការពារក្តីស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់សារណាជាលាយលក្ខណ៍អក្សរ អនុលោមតាមវិធាន ១១១, ១១២ និង ១១៣" ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១២ ("សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុង*រឿងក្តី Taylor*") កថាខណ្ឌ ២៥។

[17] សេចក្តីសម្រេចលើការបន្ថែមចំនួនទំព័រកំណត់ក្នុង*រឿងក្តី Karadžić* ទំព័រ ២ និង សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុង*រឿងក្តី Taylor*") កថាខណ្ឌ ២៦។

[18] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba Gombo និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICC-01/05-01/13-2046 "សេចក្តីសម្រេចលើសំណើសុំពេលវេលាបន្ថែមដើម្បីដាក់ជូនឯកសារគាំទ្របណ្តឹងសាទុក្ខ" ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង*រឿងក្តី Bemba*") កថាខណ្ឌ ១៨។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba Gombo* សំណុំរឿងលេខ ICC-01/05-01/08-3370 "សេចក្តីសម្រេចលើសំណើ *Bemba* សុំពេលវេលាបន្ថែមដើម្បីដាក់ជូនឯកសារគាំទ្របណ្តឹងសាទុក្ខ" ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង*រឿងក្តី Bemba*") កថាខណ្ឌ ៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba* សំណុំរឿងលេខ ICC-01/05-01/08-3405 "សេចក្តីសម្រេចលើសំណើរបស់លោក Bemba សុំបន្ថែមចំនួនទំព័រកំណត់សម្រាប់ឯកសាររបស់គាត់ក្នុងការគាំទ្របណ្តឹងសាទុក្ខ" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ("សេចក្តីសម្រេចលើការបន្ថែមចំនួនទំព័រកំណត់ក្នុង*រឿងក្តី Bemba*") កថាខណ្ឌ ១០។ សេចក្តីសម្រេចលើការបន្ថែមចំនួនទំព័រកំណត់ក្នុង*រឿងក្តី Lubanga* កថាខណ្ឌ ៥។ សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង*រឿងក្តី Šainović* ទំព័រ ៤។ សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរ និងពេលវេលាកំណត់ក្នុង*រឿងក្តី Prlić* ទំព័រ ២។ សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង*រឿងក្តី Karadžić* ទំព័រ ២។ សេចក្តីសម្រេចលើ

ទណ្ឌដែលគ្របដណ្ដប់ទៅលើទីតាំងភូមិសាស្ត្រចម្រុះ[20] និង ការតែងតាំងមេធាវីការពារក្ដីថ្មី[21] បង្កើតបានជាមូលហេតុសមស្របសម្រាប់អនុញ្ញាតឲ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រ ដែលបានកំណត់ក្នុងនីតិវិធី។ ការខ្វះខាតផ្នែកធនធានសម្រាប់មេធាវីការពារក្ដី[22] និង តួនាទីក្នុងឋានានុក្រម ឬ ឋានៈដ៏ខ្ពង់ខ្ពស់របស់ជនជាប់ចោទក៏ត្រូវបានពិចារណា នៅក្នុងការ ផ្លាស់ប្ដូរការកំណត់ក្នុងនីតិវិធីនេះដែរ[23]។

## ផ្នែកទី ៤. ទឡ្ហីករណ៍

## I. ការស្នើសុំបន្ថែមពេលវេលា និង ចំនួនទំព័រ ជាការចាំបាច់ដើម្បីការពារសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌

### ក. លោក នួន ជា ត្រូវមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីរៀបចំការការពារក្ដីរបស់ខ្លួន

---

ការបន្ថែមពេលវេលាកំណត់ក្នុង *រឿងក្ដី* *Karadžić* ទំព័រ ២។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Fofana* *និង* *Kondewa* សំណុំរឿងលេខ SCSL-04-14-A “សេចក្ដីសម្រេចលើញត្តិរួមគ្នារបស់មេធាវីការពារក្ដី និងរដ្ឋអាជ្ញាស្នើសុំការបន្ថែមពេលវេលាកំណត់សម្រាប់ការសារណាបណ្ដឹងសាទុក្ខ និងការបន្ថែមចំនួនទំព័រកំណត់សម្រាប់សារណាបណ្ដឹងសាទុក្ខ” ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៧ (“សេចក្ដីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុង *រឿងក្ដី* *Fofana*”) ទំព័រ ៤ និង សេចក្ដីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុង *រឿងក្ដី* *Taylor* កថាខណ្ឌ ២៥។

[19] សេចក្ដីសម្រេចលើការបន្ថែមចំនួនទំព័រកំណត់ក្នុង *រឿងក្ដី* *Bemba* កថាខណ្ឌ ១០ និង សេចក្ដីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង *រឿងក្ដី* *Karadžić* ទំព័រ ២។

[20] សេចក្ដីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង *រឿងក្ដី* *Šainović* ទំព័រ ៤ និង សេចក្ដីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុង *រឿងក្ដី* *Taylor* កថាខណ្ឌ ២៦។

[21] សេចក្ដីសម្រេចលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុង *រឿងក្ដី* *Fofana* ទំព័រ ៣។

[22] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Karadžić* សំណុំរឿងលេខ MICT-13-55-A “សេចក្ដីសម្រេចលើញត្តិស្នើសុំការពន្យារពេលបន្ថែមដើម្បីដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ” ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ទំព័រ ៣។

[23] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Šainović* *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ TI-05-87-A “សេចក្ដីសម្រេចលើញត្តិស្នើសុំការបន្ថែមពេលវេលាដើម្បីដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍” ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ ទំព័រ ៣ *និង រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Karadžić* សំណុំរឿងលេខ MICT-13-55-A “សេចក្ដីសម្រេចលើញត្តិស្នើសុំការបន្ថែមពេលវេលាដើម្បីដាក់សេចក្ដីជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍” ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ទំព័រ ១។

១៣. សំណើនេះគួរតែត្រូវបានយកមកពិនិត្យ ដោយគិតទៅដល់សិទ្ធិរបស់បុគ្គលក្នុងការទទួលបានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្ដីរបស់ខ្លួន។ គោលការណ៍នេះ គឺជាការធានាជាអប្បបរិមាមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលមានចែងនៅមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងទទួលស្គាល់ដោយ អ.វ.ត.ក និង តុលាការអន្តរជាតិផ្សេងទៀត និង ដោយប្រទេសកម្ពុជាដូចមានក្នុងរដ្ឋធម្មនុញ្ញរបស់ខ្លួន។

១៤. តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) បានសម្រេចជាដដែលៗថា បទប្បញ្ញត្តិ ស្ដីអំពីសិទ្ធិមនុស្ស ដោយរាប់បញ្ចូលទាំងសិទ្ធិទទួលបានការកាត់សេចក្ដីដោយយុត្តិធម៌ផង គឺ“មានបំណងធានានូវសិទ្ធិដែលពិតប្រាកដ និងជាក់ស្ដែង តែមិនមែនសិទ្ធិដែលមានគ្រាន់តែជាទ្រឹស្ដី និងស្រមើស្រម៉ៃនោះទេ”[24]។ តុលាការ ECtHR បន្ថែមទៀតថា ដើម្បីកំណត់ថា ពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ សម្រាប់បុគ្គលមួយក្នុងការរៀបចំការការពារក្ដី នោះអង្គជំនុំជម្រះត្រូវតែពិចារណាថា តើពេលវេលា និង មធ្យោបាយដែលបានស្នើឡើងនេះ មានលក្ខណៈគ្រប់គ្រាន់ពិតប្រាកដ និងជាក់ស្ដែងក្នុងការៀបចំការការពារក្ដីប្រកបដោយប្រសិទ្ធភាពដែរឬទេ។

១៥. អនុលោមតាមគោលជំហររបស់តុលាការ ECtHR អង្គជំនុំជម្រះនេះបានផ្ដល់ពេលវេលា និង ចំនួនទំព័របន្ថែមដល់ចុងចោទទាំងពីររូប ក្នុងការដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ដើម្បីធានាឲ្យមាន “ពេលវេលា និងចំនួនទំព័រគ្រប់

---

[24] *រឿងក្ដី Artico តទល់នឹង ប្រទេសអ៊ីតាលី* តុលាការ ECtHR ពាក្យសុំលេខ 6694/74 “សាលក្រម” ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៨០ កថាខណ្ឌ ៣៣ (គូសបញ្ជាក់បន្ថែម) (សូមមើល ឯកសារ **F40/1.1.1.5**)។

គ្រាន់សម្រាប់ការលើកឡើងប្រកបដោយអត្ថន័យ"[25]។ អង្គជំនុំជម្រះបានសម្រេចបន្ថែមថា ចំនួនទំព័រកំណត់ "ត្រូវតែកំណត់ទៅតាមសេចក្តីត្រូវការចាំបាច់របស់ភាគី"[26]។

១៦. អង្គជំនុំជម្រះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា ក៏បានទទួលស្គាល់ស្រដៀងគ្នាដែរ នូវសិទ្ធិរបស់ភាគីវិវាទក្នុងការទទួលបានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ ក្នុងការដាក់សារណាបណ្តឹងសាទុក្ខ[27]។ ឧទាហរណ៍ ចៅក្រមអង្គបុរេសាទុក្ខនៅក្នុង*រឿងក្តី Prlić និងអ្នកផ្សេងទៀត* បានសម្រេចថា ជា "ប្រយោជន៍យុត្តិធម៌ដែលត្រូវធានាថា ភាគីទទួលបានពេលវេលាគ្រប់គ្រាន់ក្នុងការរៀបចំសារណាឲ្យមានប្រសិទ្ធភាព ដែលស្របយ៉ាងពេញលេញទៅនឹងបទប្បញ្ញត្តិពាក់ព័ន្ធ"[28]។

១៧. ហេតុនេះ ជាការធានាអប្បបរមានៃសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ លោក នួន ជា មានសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ ក្នុងការរៀបចំសារណាបណ្តឹងសាទុក្ខរបស់គាត់ អនុលោមទៅតាមវិធាន អ.វ.ត.ក ដែលពាក់ព័ន្ធ។ ពាក់ព័ន្ធនឹងចំណុចនេះ ពេលវេលា និងចំនួនទំព័រដែលបានកំណត់នៅក្នុងបទប្បញ្ញត្តិបច្ចុប្បន្ន ដើម្បីដាក់សារណាបណ្តឹងសាទុក្ខ ពុំគ្រប់គ្រាន់ទេ។ ពេលវេលា និងចំនួនទំព័រកំណត់ត្រូវធ្វើការកែប្រែដើម្បីធានាថា លោក នួន ជា មានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ដើម្បីដាក់សេចក្តី

---

[25] ឯកសារ **F9** "សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤ ("សេចក្តីសម្រេចលើកទីពីរលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់") កថាខណ្ឌ ១៣។

[26] ឯកសារ **F13/2** "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប" ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៥។

[27] សូមមើល ឧទាហរណ៍ សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង*រឿងក្តី Karadžić* ទំព័រ ២។ សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង*រឿងក្តី Karadžić* ទំព័រ ២។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mladić* សំណុំរឿងលេខ MICT-13-56-A "សេចក្តីសម្រេចលើញត្តិរបស់ Ratko Mladić ស្នើសុំបន្ថែមពេលវេលា និងចំនួនអក្សរកំណត់" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ ("សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ក្នុង*រឿងក្តី Mladić*") ទំព័រ ៤។

[28] សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ក្នុង*រឿងក្តី Prlić* ទំព័រ ៣។ សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ក្នុង*រឿងក្តី Mladić* ទំព័រ ៤។

សន្និដ្ឋានប្រកបដោយអត្ថន័យនៅចំពោះមុខអង្គជំនុំជម្រះ និងដើម្បីកុំឱ្យសិទ្ធិរបស់លោក នួន ជា ក្នុងការប្ដឹងសាទុក្ខនៅត្រឹមតែជាទ្រឹស្ដី។ ការពិត អង្គជំនុំជម្រះហាក់ដូចជាបានទទួលស្គាល់រួចមកហើយនូវទំហំ និងភាពស្មុគ្រស្មាញនៃកាតព្វកិច្ចក្នុងការរៀបចំសារណាបណ្ដឹងសាទុក្ខ។ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនបដិសេធសំណើរបស់ក្រុមមេធាវីការពារក្ដី ខៀវ សំផន ដែលសុំឱ្យពិចារណាសេចក្ដីសម្រេចរបស់ខ្លួនឡើងវិញអំពីការកំណត់ចំនួនទំព័រ និងពេលវេលាសម្រាប់ការជូនដំណឹងអំពីបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះបានកត់សម្គាល់ថា "ការរៀបចំសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ គឺជានីតិវិធីមួយក្នុងគោលបំណងកម្រិតអំពីពេលវេលា និងខ្លឹមសារ បើធៀបទៅនឹងការរៀបចំ និងការដាក់*សារណា*នៃបណ្ដឹងសាទុក្ខ*ដែលមានសំអាងហេតុពេញលេញ*"[29]។

## ខ. នេះជាឱកាសចុងក្រោយសម្រាប់លោក នួន ជា ក្នុងការការពារក្ដីរបស់ខ្លួន

១៨. សំណុំរឿងនេះមិនមែនត្រឹមតែជាសំណុំរឿងចុងក្រោយប្រឆាំងនឹង នួន ជា នៅ អ.វ.ត.ក ហើយអាចជាសំណុំរឿងចុងក្រោយទាំងអស់នៅ អ.វ.ត.ក ប៉ុណ្ណោះទេ តែបណ្ដឹងសាទុក្ខនេះគឺជាដំណាក់កាលចុងក្រោយនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងសមាជិកថ្នាក់កំពូល និងមានឋានៈខ្ពស់បំផុតនៃបក្សកុម្មុយនីស្ដកម្ពុជាដែលនៅរស់រានមានជីវិត។ ហេតុនេះ វាជាឱកាសចុងក្រោយសម្រាប់ អ.វ.ត.ក ក្នុងការស្វែងរកការពិតអំពីព្រឹត្តិការណ៍នានាដែលបានកើតឡើងក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។

១៩. ទោះបីកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ពាក់ព័ន្ធនឹងសក្ខីកម្មជាច្រើន និងការបង្ហាញសារណាផ្ទាល់មាត់នានាក៏ដោយ តែសារណាបណ្ដឹងសាទុក្ខមានចំណុចស្នូលនៃរឿងក្ដីរបស់លោក នួន ជា អំពីបណ្ដឹងសាទុក្ខ និងជាមូលដ្ឋានចម្បងសម្រាប់អង្គជំនុំជម្រះយកទៅរៀបចំសាលដីកា។ នៅក្នុងបរិបទនេះ នៅពេលមានសារណាបណ្ដឹងសាទុក្ខដែលស៊ីសង្វាក់គ្នា វានឹងជួយដល់

---

[29] ឯកសារ F44/1 "សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំឱ្យពិចារណាឡើងវិញនូវសេចក្ដីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ទំព័រ ៤-៥ (គូសបញ្ជាក់បន្ថែម)។

អង្គជំនុំជម្រះក្នុងការចេញសេចក្ដីសម្រេច ជួយសម្រួលនូវដំណើរការទាំងមូលនៃកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ និង ផ្ដល់នូវប្រសិទ្ធភាពជាក់ស្ដែងដល់សិទ្ធិរបស់លោក នួន ជា ក្នុងការការពារក្ដីរបស់ខ្លួន។ ដោយពិចារណាទៅលើវិសាលភាព និងភាពស្មុគស្មាញនៃរឿងក្ដី និងមូលដ្ឋាននៃបណ្ដឹងសាទុក្ខរបស់លោក នួន ជា វាតម្រូវឲ្យមានការតាក់តែងឯកសារមួយយ៉ាងវែងចៀសមិនរួចឡើយ។

## គ. សេដ្ឋកិច្ចតុលាការមិនត្រូវមានទម្ងន់ជាងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីឡើយ

២០. ជាងនេះទៅទៀត មេធាវីការពារក្ដីសូមគូសបញ្ជាក់ថា ទោះបីជាសេដ្ឋកិច្ចតុលាការជាការពិចារណាសំខាន់នៅក្នុងដំណើរការនៃកិច្ចដំណើរការនីតិវិធីក៏ដោយ ក៏ត្រូវតែមិនឲ្យប៉ះពាល់ដល់ភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់បុគ្គលក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ។ ដូចដែលតុលាការ ECtHR កត់សម្គាល់លើបញ្ហានេះនៅក្នុង*រឿងក្ដី Papadakis តទល់នឹង អតីតសាធារណរដ្ឋម៉ាសេដូនីនៃយូហ្គោស្លាវី* រួចហើយ ក្ដីបារម្ភអំពីលទ្ធភាពនៃការពន្យារពេលនីតិវិធី “មិនអាចជាយុត្តិកម្មចំពោះការកម្រិតដ៏ធ្ងន់ធ្ងរទៅលើសិទ្ធិការពារក្ដីរបស់ដើមបណ្ដឹងនោះទេ” ពីព្រោះ “សិទ្ធិទទួលបានភាពត្រឹមត្រូវនៅក្នុងវិស័យយុត្តិធម៌ គឺចាំបាច់ត្រូវតែមាននៅក្នុងសង្គមប្រជាធិបតេយ្យ ហើយដែលមិនអាចបោះបង់ចោលដើម្បីពន្លឿននីតិវិធីនោះទេ”[30]។ ដូចគ្នានេះដែរនៅក្នុង *រឿងក្ដី OAO Neftyanaya Kompaniya Yukos តទល់នឹង ប្រទេសរុស្ស៊ី* តុលាការ ECtHR បានសម្រេចថា ទាក់ទងនឹងពេលវេលាដែលបែងចែកដល់មេធាវីការពារក្ដីដើម្បីអានសំណុំរឿងនៅមុនពេលសវនាការ ថា “បើទោះជាវា [...] មានសារសំខាន់នៅក្នុងការដំណើរការនីតិវិធីនៅក្នុងល្បឿនមួយល្អ តែវាមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិនីតិវិធីនៃភាគីណាមួយនោះទេ”[31]។

---

[30] *រឿងក្ដី Papadakis តទល់នឹង អតីតសាធារណរដ្ឋម៉ាសេដូនីនៃយូហ្គោស្លាវី* តុលាការ ECtHR ពាក្យសុំលេខ 50254/07 “សាលក្រម” ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ៩៤ (*សូមមើល* ឯកសារ **E409.1.2**)។

[31] *រឿងក្ដី OAO Neftyanaya Kompaniya Yukos តទល់នឹង ប្រទេសរុស្ស៊ី* តុលាការ ECtHR ពាក្យសុំលេខ 14902/04 “សាលក្រម” ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ៥៤០ (*សូមមើល* ឯកសារ **F40/1.1.1.6**)។

២១. នៅក្នុងការសម្រេចរបស់ខ្លួនទៅលើសំណើនេះ អង្គជំនុំជម្រះក៏ត្រូវបែងចែកឱ្យដាច់រវាង "សេដ្ឋកិច្ចតុលាការ" និង "ភាពងាយស្រួលផ្នែកតុលាការ" ដែរ។ នៅក្នុង*រឿងក្តី Burmych និង Ors តទល់នឹង ប្រទេសអ៊ុយក្រែន* តុលាការ ECtHR បានថ្កោលទោសដល់ការបំពារបំពានទៅលើសញ្ញាណនៃ "សេដ្ឋកិច្ចតុលាការ" ទៅតាមពាក្យពេចន៍ដូចខាងក្រោម៖

> ទោះបីមានការថយចុះនូវចំនួនរឿងក្តីដែលរង់ចាំការសម្រេចនៅតុលាការអាចធ្វើឱ្យស្ថានភាពរដ្ឋបាលរបស់ស្ថាប័នមានភាពប្រសើរជាងមុនក្តី តែចំណុចនេះពុំមែនមានន័យថាស្ថានភាពសិទ្ធិមនុស្សនៅទ្វីបអឺរ៉ុបមានភាពប្រសើរជាងមុននោះឡើយ។ ផ្ទុយទៅវិញទេ! តុលាការត្រូវបានបង្កើតឡើងជាពិសេស ដើម្បីឆ្លើយតបទៅនឹងការរំលោភបំពានទាំងនេះ ក្នុងនាមជាស្ថាប័នតុលាការឯករាជ្យ និងមិនផ្តោតទៅលើស្ថិតិទេ។ [...] **ការខកខានមិនបានដោះស្រាយបញ្ហាករណីរំលោភសិទ្ធិជាសារវ័ន្តទាំងនោះក៏មិនអាចធ្វើចំណាត់ប្រភេទនៅក្រោមសេដ្ឋកិច្ចតុលាការ ប្រសិទ្ធផលតាមផ្លូវតុលាការ** ឬទស្សនវិជ្ជារបស់ Brighton ទេ។ **ចំណុចនេះគ្រាន់តែជាភាពងាយស្រួលផ្នែកតុលាការមួយរយៈខ្លីតែប៉ុណ្ណោះ**[32]។

២២. ហេតុនេះ ការពិចារណាពីបញ្ហាថវិកា ឬផែនការបញ្ចប់របស់ អ.វ.ត.ក មិនគួរក្លាយជាផ្នែកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់លោក នួន ជា ឡើយ។ ហើយកត្តាទាំងនេះក៏មិនអាចស្ថិតក្នុងវង្វង់សមត្ថកិច្ចនៃសេដ្ឋកិច្ចតុលាការដែរ។ ទោះបី "ដំណើរការដ៏មានប្រសិទ្ធភាពរបស់ [អ.វ.ត.ក] កន្លងមកត្រូវបានរំខានដោយរឿងខ្វះខាតថវិកា"[33] ក៏ដោយ ក៏អង្គជំនុំជម្រះធ្លាប់បានសង្កត់ធ្ងន់រួចហើយថា៖

> ដោយហេតុថា ចៅក្រមនៅគ្រប់ពេលទាំងអស់ ជាក់ច្បាស់ណាស់ ត្រូវមានកាតព្វកិច្ចពិចារណាលើប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ដូច្នេះចៅក្រម ជានិច្ចកាលត្រូវ

---

[32] *រឿងក្តី Burmych និងអ្នកផ្សេងទៀត តទល់នឹង ប្រទេសអ៊ុយក្រែន* តុលាការ ECtHR ពាក្យសុំលេខ 46852/13 និងពាក្យសុំផ្សេងទៀត "សាលក្រម" ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៣៩ (**ឯកសារភ្ជាប់ ១**) (គូសបញ្ជាក់បន្ថែម)។

[33] ផែនការបញ្ចប់របស់ អ.វ.ត.ក (វិសោធនកម្មទី ២០) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ១៤ (**ឯកសារភ្ជាប់ ២**)។

អនុវត្តទៅតាមវិសាលភាពនៃច្បាប់ ដែលជាគោលការណ៍ ដែលមានលក្ខណៈសំខាន់ជាងការសន្សំសំចៃផ្នែកថវិកា។ [...] ប្រសិនបើពុំមានថវិកាគ្រប់គ្រាន់ ក្នុងការធានានូវការជំនុំជម្រះដែលច្បាប់បានតម្រូវនោះទេ រាល់កិច្ចដំណើរការនីតិវិធីត្រូវតែបញ្ចប់ ហើយតុលាការត្រូវបិទទ្វារ។ ដើម្បីរាំងរល់បញ្ហានេះ កិច្ចដំណើរការនីតិវិធីត្រូវបន្តដោយពុំមានសេចក្តីសម្រេចណាមួយលើអង្គច្បាប់ និងអង្គហេតុ ត្រូវទទួលរងនូវឥទ្ធិពលដោយឥតសមស្របពីបញ្ហាហិរញ្ញវត្ថុឡើយ[34]។

២៣. មេធាវីការពារក្តីកត់សម្គាល់ថា ផែនការបញ្ចប់បច្ចុប្បន្នបានកំណត់ពីតារាងថិរវេលាដែលរំពឹងទុកសម្រាប់ដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅឆ្នាំ២០១៩ ហើយការចេញសាលដីកាត្រឹមបំណាច់ត្រីមាសទីបួន នៅឆ្នាំ២០២០[35]។ ដោយពិចារណាថា អង្គជំនុំជម្រះបានចំណាយពេល ២១ ខែដើម្បីចេញសាលដីកាក្នុងសំណុំរឿង ០០២/០១ ដែលមានវិសាលភាពចង្អៀតជាងនេះ ជាការពិតដែលថា កាលបរិច្ឆេទដែលរំពឹងទុកសម្រាប់ចេញសាលដីកាក្នុងសំណុំរឿង ០០២/០២ នឹងត្រូវពន្យារពេលជាច្រើនទៀត។ ហេតុនេះ មេធាវីការពារក្តីពុំគួរត្រូវបានកំណត់កាលបរិច្ឆេទដែលមិនសមហេតុផល និងមិនយុត្តិធម៌សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដើម្បីបំពេញទៅតាមសេចក្តីពិចារណាគោលនយោបាយបច្ចុប្បន្នដែលមិនស្របទៅនឹងសភាពជាក់ស្តែងនៃកិច្ចដំណើរការនីតិវិធីទាំងនេះទាល់តែសោះនោះទេ ហើយច្បាស់ណាស់ត្រូវតែធ្វើការកែប្រែទើបបាន។

២៤. គួរគូសបញ្ជាក់ផងដែរថា សារណាជាច្រើនរបស់សហព្រះរាជអាជ្ញាមិនស្ថិតក្រោមការរឹតត្បិតនៃសេដ្ឋកិច្ចតុលាការទេ រួមមាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួននៅក្នុងសំណុំរឿង ០០២។ ប្រការនេះធ្វើឲ្យសហព្រះរាជអាជ្ញាមានឥទ្ធិពលយ៉ាងធំធេង ទៅលើកិច្ចដំណើរការនីតិវិធីទាំងមូល។ លោក

---

[34] ឯកសារ **E284/4/8** "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២" ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៧៥។

[35] ផែនការបញ្ចប់របស់ អ.វ.ត.ក (វិសោធនកម្មទី ២០) ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ កថាខណ្ឌ ១២(i) និង ៣៨ សម្រាប់ការដាក់បណ្តឹងសាទុក្ខ និង កថាខណ្ឌ ១២(ii) និង ៣៩ សម្រាប់ការចេញសាលដីកា។

នួន ជា បានជាប់ក្នុងមន្ទីរឃុំឃាំងតាំងពីឆ្នាំ២០០៧ មកម្ល៉េះ។ ការណ៍ដែលសំណុំរឿង ០០២ ត្រូវបានដំណើរការក្នុងរយៈពេលដ៏យូរបែបនេះ ជាបញ្ហាដែលគាត់មិនអាចត្រួតពិនិត្យបានទាស់តែសោះ។ តាមពិត ប្រសិនបើមានការសង្កត់ធ្ងន់ទៅលើចិរវេលាតាំងពីដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី ឬការបំបែកកិច្ចដំណើរការនីតិវិធីដែលមានភាពតំណាងសមហេតុផលចំពោះសំណុំរឿង ០០២ ដោយអង្គជំនុំជម្រះសាលាដំបូងតាំងពីដំបូងមក ក្តីព្រួយបារម្ភទាំងនេះមានលក្ខណៈសមស្របតិចតួចណាស់នៅពេលនេះ។ នាពេលនេះ បន្ទុកនៃ "សេដ្ឋកិច្ចតុលាការ" មិនគួរដាក់ទៅលើមេធាវីការពារក្តីទេ នៅពេលដែលមេធាវីការពារក្តីមានឱកាសតិចតួចជាងសហព្រះរាជអាជ្ញាក្នុងការការពារក្តី ជាពិសេស ប្រសិនបើការដាក់បន្ទុកនោះនឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់លោក នួន ជា ក្នុងការការពារក្តីរបស់ខ្លួនប្រកបប្រសិទ្ធភាព។

២៥. ចុងក្រោយ *តាមឆន្ទៈរបស់ខ្លួន* អង្គជំនុំជម្រះក៏ត្រូវបញ្ចៀសការពិចារណាទៅលើវ័យចាស់ជរា និងសុខភាពរបស់លោក នួន ជា ជាបញ្ហាពាក់ព័ន្ធនឹងសេដ្ឋកិច្ចតុលាការដែរ។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនដែលបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ អង្គជំនុំជម្រះបានសម្រេចថា វ័យចាស់ជរា និងសុខភាពរបស់ជនជាប់ចោទតម្រូវឲ្យភាគីបំពេញការងារប្រកបដោយការយកចិត្តទុកដាក់[36]។ ទោះជាយ៉ាងណាក្តី វ័យចាស់ជរា និងសុខភាពរបស់លោក នួន ជា គឺជាកត្តាដែលគាត់ និងមេធាវីការពារក្តីតែប៉ុណ្ណោះដែលត្រូវយកមកពិចារណា។ អង្គជំនុំជម្រះមិនអាច និងមិនគួរប្រើប្រាស់កត្តាទាំងនេះ ដើម្បីធ្វើឲ្យប៉ះពាល់ដល់លទ្ធភាពរបស់លោក នួន ជា ក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការការពារក្តីរបស់គាត់ ហើយក៏មិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីការពារក្តីរបស់ខ្លួនដែរ ជាពិសេសនៅពេលដែលមេធាវីការពារក្តីជាអ្នកដែលសក្តិសមជាងគេ ក្នុងការកំណត់ពីពេលវេលាដែលចាំបាច់ដើម្បីរៀបចំបណ្តឹងសាទុក្ខរបស់លោក នួន ជា។

## II. សំណើសុំពេលវេលា និងចំនួនទំព័របន្ថែម គឺត្រឹមត្រូវ និងសមហេតុផល

---

[36] ឯកសារ F43 សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ១០។

## ក. សាលក្រម និង សំណុំរឿងមានភាពស្មុគស្មាញ និង ទូលំទូលាយ

### ១. វិសាលភាពនៃបណ្តឹងសាទុក្ខ

២៦. ទំហំនៃសាលក្រម និងសំណុំរឿងជាមូលដ្ឋានត្រូវបានកត់សម្គាល់យ៉ាងត្រឹមត្រូវ។ ដូចដែលអង្គជំនុំជម្រះនេះបានទទួលស្គាល់នៅពេលសម្រេចបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខថា៖

> សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំនួន ៤.១០១ ទំព័រ ជាភាសាខ្មែរ ២.៣៨៧ ទំព័រ ជាភាសាអង់គ្លេស និង ២.៨២៨ ទំព័រ ជាភាសាបារាំង គឺជាសាលក្រមដែលវែងជាងគេបំផុត ដែលបានធ្វើឡើងនៅ អ.វ.ត.ក ហើយទំហំនេះគឺប្រហាក់ប្រហែលនឹងសាលក្រមនានា នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមួយចំនួនដែលស្មុគស្មាញជាងគេ ដែលត្រូវបានជំនុំជម្រះនៅចំពោះមុខតុលាការអន្តរជាតិផ្សេងទៀត។ **ទំហំ និងភាពស្មុគស្មាញដែលមិនធ្លាប់មានពីមុន** នៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ ត្រូវបានគូសបញ្ជាក់តាមរយៈកត្តានានាដូចជារយៈពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ ចំនួនសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានមកផ្តល់ភស្តុតាងនៅក្នុងសវនាការ ចំនួនវត្ថុតាងដែលបានដាក់ និងដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណា វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃបទចោទ និងភាពថ្មីប្លែកនៃបញ្ហាមួយចំនួន ដែលត្រូវបានចោទប្រកាន់នៅក្នុងសវនាការ ជាលើកដំបូងបំផុតសម្រាប់ អ.វ.ត.ក[37]។

២៧. បណ្តឹងសាទុក្ខរបស់លោក នួន ជា ក៏មានភាពទូលំទូលាយដូចគ្នាដែរ ដោយមេធាវីការពារក្តីបានបង្ហាញកំហុសយ៉ាងហោចណាស់ចំនួន ៥៤៣ ដែលកើតមាននៅក្នុងសាលក្រម និងដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់ពិនិត្យលើបណ្តឹងសាទុក្ខ រួមទាំង សេចក្តីសម្រេចចំនួន ២៤ ដែលបានចេញក្នុង

---

[37] ឯកសារ F43 សេចក្តីសម្រេចលើការសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២ កថាខណ្ឌ ៨ (គូសបញ្ជាក់បន្ថែម)។

អំឡុងពេលជំនុំជម្រះ[38]។ ជាការប្រៀបធៀបគឺថា សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ មានមូលដ្ឋានបណ្ដឹងសាទុក្ខចំនួន ២២៣[39]។

២៨. អង្គជំនុំជម្រះធ្លាប់បានសម្រេចពីមុនមកថា "ការពន្យារពេលដែលស្នើឡើងសម្រាប់ [...] សារណាបណ្ដឹងសាទុក្ខ ត្រូវស្របគ្នាទៅនឹងទំហំនៃបណ្ដឹងសាទុក្ខរបស់ម្ចាស់បណ្ដឹងសាទុក្ខ"[40]។ ហេតុនេះ ការពន្យារពេល និងបន្ថែមចំនួនទំព័រត្រូវតែផ្ដោតទៅលើវិសាលភាពដែលបានស្នើឡើងនៃបណ្ដឹងសាទុក្ខរបស់មេធាវី ដោយផ្ដល់នូវពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ដើម្បីបង្ហាញពីមូលដ្ឋាននីមួយៗ អនុលោមទៅតាមវិធានផ្ទៃក្នុង[41]។ ហេតុនេះ និងស្របគ្នាទៅនឹងវិសាលភាពនៃបណ្ដឹងសាទុក្ខនេះ មេធាវីត្រូវការយ៉ាងសមរម្យនូវពេលវេលាយ៉ាងហោចណាស់ ១០,៥ ខែ ចាប់ពីពេលដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ (គឺ បន្ថែមរយៈពេល ៨,៥ ខែ) ចំនួន ១.០០០ ទំព័រ (គឺ បន្ថែមចំនួន ៩៧០ ទំព័រ) ដើម្បីដាក់សារណាបណ្ដឹងសាទុក្ខរបស់ខ្លួន។

## ២. ពុំមានបណ្ដឹងសាទុក្ខបន្ទាន់បង្គំ

២៩. ជាផ្នែកបណ្ដឹងសាទុក្ខរបស់ខ្លួន មេធាវីការពារក្ដីបានបង្ហាញថាមានសេចក្ដីសម្រេចចំនួន ២៤ ត្រូវបានចេញក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ដែល

---

[38] ឯកសារ **E465/3/1** សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ទំព័រ ១០។ មូលដ្ឋាន ៩ រៀបរាប់នូវសេចក្ដីសម្រេចនានាដូចតទៅ៖ E336/3, E346/2/2, E346/3, E347/4, E350/8, E367, E370/4, E380/2, E388, E395/1, E396/4, E399/5, E405/2, E408/4, E408/5, E409/3, E415, E416/4, E418/3, E443/10, E444/1, E449/3/6, E457/6, E459។

[39] ឯកសារ **F36** "បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ ("សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១")។

[40] ឯកសារ **F3/3** "សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំពន្យារពេល និងបន្ថែមចំនួនទំព័រលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និងសារណានៃបណ្ដឹងសាទុក្ខ" ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ("សេចក្ដីសម្រេចលើការពន្យារពេល និងបន្ថែមទំព័រ នៅក្នុងសំណុំរឿង ០០២/០១") កថាខណ្ឌ ១០។

[41] *សូមមើល* ជាពិសេស វិធាន ១០៥(៣) នៃវិធានផ្ទៃក្នុង។

ខ្លួនយល់ថា បានរំលោភបំពានទៅលើសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ដោយសារពុំអាចដាក់បណ្តឹងសាទុក្ខបន្ទាន់បង្ហំនៅ អ.វ.ត.ក បាន ប្រការនេះមានន័យថា សេចក្តីសម្រេចទាំងនេះនឹងត្រូវលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខវិញ។ ប្រសិនបើអាចប្តឹងសាទុក្ខទៅលើសេចក្តីសម្រេចទាំងនោះក្នុងអំឡុងពេលជំនុំជម្រះបាន មេធាវីការពារនឹងទទួលបានផលប្រយោជន៍ពីការកំណត់ចំនួន ៣០ ទំព័រសម្រាប់បណ្តឹងសាទុក្ខបន្ទាន់បង្ហំនីមួយៗមិនខាន[42]។ ទាក់ទិននឹងចំនួនសេចក្តីសម្រេចផ្នែកនីតិវិធីដែលរងការជំទាស់ដែលបានលេចឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ចំណុចនេះត្រូវបញ្ចូលទៅក្នុងសារណាដែលមានចំនួនដល់ទៅ ៧២០ ទំព័រឯណោះ។

៣០. អង្គជំនុំជម្រះនេះបានសង្កត់ធ្ងន់ថា បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចទាំងនេះ "ត្រូវបង្ហាញពី*ការប៉ះពាល់*ជានិរន្តរបស់ម្ចាស់បណ្តឹងសាទុក្ខ។ ដូច្នេះ បណ្តឹងសាទុក្ខនៃសេចក្តីសម្រេចនេះ ត្រូវតែជាប់ទាក់ទងទៅទង្វីករណ៍មួយ ឬច្រើននៃបណ្តឹងសាទុក្ខលើសាលក្រម"[43]។ នាពេលនេះ ដោយសារសាលក្រមបានចេញរួចហើយ ផលប៉ះពាល់ពេញលេញនៃសេចក្តីសម្រេចផ្នែកនីតិវិធី ដែលបានចេញក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះបានលេចចេញជារូបរាង ដូចបានបង្ហាញនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន[44]។ ហេតុនេះ មេធាវីការពារក្តីត្រូវការបន្ថែមចំនួនទំព័រយ៉ាងសមរម្យ ដើម្បីលើកឡើងនូវសេចក្តីសម្រេចទាំងនោះមួយម្តងៗ។

## ៣. ទិន្នន័យប្រៀបធៀប

៣១. នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូងបានចេញសាលក្រមដែលមានចំនួន ២.២៥៩ ទំព័រ ទៅលើសំណុំរឿង ០០២/០២ រយៈពេល ២៦ ខែ ក្រោយពេលបញ្ចប់សវនាការ

---

[42] ឯកសារ **F9** សេចក្តីសម្រេចលើកទីពីរលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៦។

[43] ឯកសារ **F9** សេចក្តីសម្រេចលើកទីពីរលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១៦។

[44] ឯកសារ **E465/3/1** សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ទំព័រ ១០ មូលដ្ឋាន ៩។

លើអង្គសេចក្តី និង រយៈពេល ២១ ខែ ក្រោយពេលធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល[45]។ ទាំងចំនួនទំព័រ និងពេលវេលាដែលអង្គជំនុំជម្រះសាលាដំបូងបានចំណាយដើម្បីចេញសាលក្រមនេះបង្ហាញពីវិសាលភាព និងភាពស្មុគស្មាញនៃបញ្ហានានាដែលពាក់ព័ន្ធ។

៣២. សំណុំរឿង ០០២/០២ គ្របដណ្តប់ទៅលើបទចោទចំនួន ២២ ដែលពាក់ព័ន្ធនឹងគោលនយោបាយនៅទូទាំងប្រទេសចំនួនប្រាំ ទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំបី និង ព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់រាប់មិនអស់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យទាំងមូល។ ភស្តុតាងចំនួនប្រហែល ១១.០០០ ត្រូវបានទទួលយកជាភស្តុតាង ហើយសាក្សីចំនួន ១៧២ បានមកផ្តល់សក្ខីកម្ម។ លោក នួន ជា មានការផ្តន្ទាទោសយ៉ាងហោចណាស់ ៧៨ ជាមួយនឹងការរាប់ដាច់ដោយឡែកចំនួនជិត ៣០០ ទោះបីជាលក្ខណៈពុំច្បាស់លាស់នៃសាលក្រម ធ្វើឲ្យមានការប្រឈមនៅក្នុងការកំណត់យ៉ាងពិតប្រាកដក៏ដោយ។ម្យ៉ាងវិញទៀត សំណុំរឿង០០២/០១ បានដោះស្រាយបទចោទចំនួនប្រាំមួយ គោលនយោបាយចំនួនមួយ (ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី ១ និងផ្នែកនៃដំណាក់កាលទី ២) និងទីតាំងឧក្រិដ្ឋកម្មចំនួនមួយ។ វត្ថុតាងចំនួនតិចជាង ៦.០០០ ត្រូវបានទទួលយក ហើយសាក្សីចំនួន ៥៨ នាក់ត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម។ សាលក្រមសំណុំរឿង ០០២/០១ ក៏ជាចំណែកតូចមួយនៃចំនួនទំព័រនៃសាលក្រមសំណុំរឿង ០០២/០២ ផងដែរ។ តែអង្គជំនុំជម្រះនៅតែយល់ឃើញថា ការបន្ថែមពេលវេលា និងចំនួនទំព័រនឹង "ចាំបាច់ត្រូវបានអនុញ្ញាត ដោយសំអាងទៅលើទំហំ និងភាពស្មុគស្មាញ" នៃសំណុំរឿងនោះ[46]។ ហេតុនេះ ចំណុចនេះមានភាពពាក់ព័ន្ធនឹងសំណុំរឿងនេះ។

៣៣. ខាងក្រោមនេះ មេធាវីការពារក្តីបានរៀបចំការប៉ាន់ស្មានពីពេលវេលា និងចំនួនទំព័រដែលចាំបាច់សម្រាប់រៀបចំសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដើម្បីលើកឡើងនូវបញ្ហាទាំងអស់ដែលបានកើតឡើងនៅក្នុងសំណុំរឿង ០០២/០២ ដោយប្រៀបធៀបទៅនឹងសំណុំរឿង ០០២/០១៖

---

[45] ឯកសារ **E465** សាលក្រម កថាខណ្ឌ ១៣។

[46] ឯកសារ **F3/3** សេចក្តីសម្រេចលើការពន្យារពេល និងបន្ថែមទំព័រ នៅក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ១០។

| | ចំនួនទំព័រក្នុងសាលក្រម | ពេលវេលាសម្រាប់សារណាបណ្តឹងសាទុក្ខ (ពីពេលដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ) | ចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ |
|---|---|---|---|
| សំណុំរឿង ០០២/០១ | ៦២៣ | ៩០ ថ្ងៃ | ២៧៩ ទំព័រ |
| សំណុំរឿង ០០២/០២ | ២.២៥៩ | ៣២៤ ថ្ងៃ | ៩៧២ ទំព័រ |
| ចំនួនដងដែលសាលក្រមសំណុំរឿង ០០២/០២ ច្រើនជាងសាលក្រមសំណុំរឿង ០០២/០១ | ៣,៦ | | |

៣៤. ដោយផ្អែកលើការគណនានេះ មេធាវីការពារក្តីទទួលការអនុញ្ញាតយ៉ាងហោចណាស់ ៣២៤ ថ្ងៃ (គឺ ប្រហែល ១១ ខែ) និង ចំនួនទំព័រអប្បបរមាចំនួន ៩៧២ សម្រាប់រៀបចំសារណាបណ្តឹងសាទុក្ខរបស់ខ្លួន។ នៅពេលរាប់ចំនួន ៣០ ទំព័របន្ថែម ដើម្បីឆ្លើយតបទៅនឹងសេចក្តីសម្រេចផ្នែកនីតិវិធីនីមួយៗក្នុងចំណោមសេចក្តីសម្រេចចំនួន ២៤ ដែលមិនត្រូវបានអនុញ្ញាតឲ្យប្តឹងសាទុក្ខបន្ទាន់បង្ហំក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ ការអនុញ្ញាតចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខកើនដល់ទៅចំនួន ១.៦៩២ ទំព័រ។

៣៥. ថ្វីត្បិតតែយ៉ាងនេះក្តី ទោះបីមេធាវីការពារក្តីត្រូវទទួលបានចំនួនទំព័រគ្រប់គ្រាន់ដើម្បីរៀបចំមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនក៏ដោយ ក៏មេធាវីការពារក្តីទទួលស្គាល់យ៉ាងពេញលេញថា គុណភាពនៃសារណាបណ្តឹងសាទុក្ខពុំមែនអាស្រ័យទៅលើប្រវែងរបស់វាទេ[47]។ ដោយសារសំអាងហេតុនេះ និងដោយសារគិតទៅដល់ចំនួន និងភាពស្មុគ្រស្មាញនៃបញ្ហានានាក្នុងបណ្តឹងសាទុក្ខ មេធាវីការពារក្តីស្នើសុំការអនុញ្ញាតត្រឹមតែ ១.០០០ ទំព័រប៉ុណ្ណោះ។ នេះជាកម្រិតអប្បបរមាដែលចាំបាច់ដើម្បីរៀបចំសារណាបណ្តឹងសាទុក្ខស៊ីចង្វាក់ ដែលគោរពដល់សិទ្ធិរបស់លោក នួន ជា ដើម្បីធ្វើការការពារក្តីយ៉ាងមានប្រសិទ្ធភាព។ ការសម្រេចអនុញ្ញាតតិចជាងនេះនឹងតម្រូវឱ្យមេធាវីការពារក្តីត្រូវបោះបង់ចោលមូលដ្ឋាននៃបណ្តឹងសាទុក្ខដែលបានរៀបចំដោយប្រុងប្រយ័ត្នរួចទៅហើយ ដែលបានបង្ហាញនៅក្នុងសេចក្តីជូនដំណឹង។

៣៦. ជាការសំខាន់គឺថា អង្គជំនុំជម្រះគួរគោរពដល់ការវាយតម្លៃផ្ទាល់របស់មេធាវីការពារក្តីចំពោះពេលវេលា និងចំនួនទំព័រដែលចាំបាច់សម្រាប់ការអនុវត្តន៍សិទ្ធិរបស់លោក នួន ជា យ៉ាងមានប្រសិទ្ធភាព។ នៅក្នុងបរិបទនៃទំហំ និងវិសាលភាពទូទៅនៃសំណុំរឿង ០០២/០២ ការស្នើសុំបន្ថែមពេល និងចំនួនទំព័រជារឿងសមហេតុផល។ ការពិត ដោយរម្លឹកថា មេធាវីការពារក្តីបានបង្ហាញកំហុសចំនួន ៥៤៣ នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង សារណាបណ្តឹងសាទុក្ខដែលមានចំនួន ១.០០០ ទំព័រ នឹងតម្រូវឱ្យមេធាវីការពារក្តីត្រូវរៀបចំ និងឆ្លើយតបយ៉ាងសមស្របចំពោះកំហុសនីមួយៗត្រឹមតែ ១,៨ ទំព័រប៉ុណ្ណោះ។ ជាការប្រៀបធៀប សហព្រះរាជអាជ្ញានឹងមានសិទ្ធិដាក់សារណាដែលមានចំនួន ៣០ ទំព័រដើម្បីគាំទ្រដល់មូលដ្ឋានតែមួយគត់នៃបណ្តឹងសាទុក្ខ។ ហេតុនេះ ការបន្ថែមពេលវេលា និងចំនួនទំព័រក៏ជាការចាំបាច់ផងដែរ ដើម្បីរក្សាសមភាពក្នុងការតទល់ក្នុងរឿងក្តី។

៣៧. តារាងខាងក្រោមបង្ហាញអំពីផលវិបាកជាក់ស្តែងការកំណត់ចំនួន ១.០០០ ទំព័រ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ និង បង្ហាញថា នៅពេលបំបែកក្នុងចំណោមផ្នែកចំនួន ២១ នៃសេចក្តី

---

[47] *សូមមើលឧទាហរណ៍* សេចក្តីសម្រេចលើការបន្ថែមចំនួនអក្សរកំណត់ក្នុង *រឿងក្តី Karadžić* ទំព័រ ២។

ជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ការកំណត់ចំនួន ១.០០០ ទំព័រ កាន់តែសមហេតុសមផលទៅទៀត។

| # | ផ្នែកនៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ | ទំព័រពាក់ព័ន្ធនៅក្នុងសាលក្រម[48] | ចំនួននៃការផ្ដន្ទាទោស | ចំនួនមូលដ្ឋាននៃបណ្ដឹងសាទុក្ខ | ចំនួនទំព័រដែលបែងចែកក្នុងមួយផ្នែកៗ ទៅតាមគម្រោងកំណត់ ចំនួន ១.០០០ ទំព័រ |
|---|---|---|---|---|---|
| ១. | ផ្នែក ១. កំហុសដែលធ្វើឲ្យមោឃភាពសាលក្រមទាំងមូល | ២.២៥៩ | ៧៨ | ១១ | ៧១ |
| ២. | សិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌ | ២.២៥៩ | ៧៨ | ២៥ | ១២៩ |
| ៣. | បរិបទប្រវត្តិសាស្ត្រ និង រចនាសម្ព័ន្ធទំនាក់ទំនងការងារ និង រចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា | ១៩៦ | ៧៨ | ៩ | ២៣ |
| ៤. | តួនាទី និង មុខងាររបស់ នួន ជា | ២៧ | ៧៨ | ៥ | ១៨ |
| ៥. | ធាតុផ្សំរួម | ៤៦ | ៧៨ | ១១ | ៤១ |
| ៦. | ច្បាប់ជាធរមាន | ៦៨ | ៧៨ | ១២ | ៣៥ |
| ៧. | គោលបំណងរួម | ១៨០ | ៧៨ | ៣៣ | ៧៦ |
| ៨. | សត្វក្រពើ | ១០២ | ៧៨ | ២៥ | ៥៩ |

---

[48] ការគណនាចំនួនទំព័រនៅក្នុងសាលក្រមពាក់ព័ន្ធនឹងផ្នែកជាក់លាក់នៃសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ រួមមានទំព័រពាក់ព័ន្ធទាំងអស់នៅក្នុងសាលក្រមដែលត្រូវបានលើកឡើងដោយផ្នែកនោះ។ ឧទាហរណ៍ តួលេខចំនួន ២៧០ ទំព័រដែលផ្ដល់ទាក់ទិននឹងសហករណ៍ត្រាំកក់ តំណាងនូវចំនួនទំព័រនៃផ្នែក ១០.១ ផ្នែក ១៦.៤.១ ផ្នែក ១៧.១.២.១ និង ផ្នែក ១៧.២.២.១។

| | | | | | |
|---|---|---|---|---|---|
| ៩. | ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល | ៥១ | ៧៨ | ៣១ | ៥៩ |
| ១០. | សហករណ៍ត្រាំកក់ | ២៧០ | ៦ | ៣០ | ៣៨ |
| ១១. | ការដ្ឋានការងារទំនប់ត្រពាំងថ្ម | ១៧៣ | ៦ | ២២ | ៣៨ |
| ១២. | ការដ្ឋានការងារទំនប់ ១ មករា | ១៦៦ | ៦ | ៥២ | ៣៨ |
| ១៣. | ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង | ១១៤ | ៥ | ៣៣ | ៣៨ |
| ១៤. | មន្ទីរសន្តិសុខ ស-២១ | ៣១៨ | ៩ | ៥១ | ៤៩ |
| ១៥. | មន្ទីរសន្តិសុខក្រាំងតាចាន់ | ១៦០ | ៨ | ៣១ | ៣៨ |
| ១៦. | មន្ទីរសន្តិសុខអូរកន្សែង | ១១១ | ៦ | ២១ | ២៦ |
| ១៧. | មន្ទីរសន្តិសុខភ្នំក្រោល | ១០២ | ៧ | ១៦ | ២៣ |
| ១៨. | ការប្រព្រឹត្តិលើពុទ្ធសាសនិក | ២៩ | ១ | ៩ | ១៨ |
| ១៩. | ការប្រព្រឹត្តិលើជនជាតិចាម | ១០៩ | ៧ | ៤១ | ៥៥ |
| ២០. | ការប្រព្រឹត្តិលើជនជាតិវៀតណាម | ៩២ | ៤ | ២៤ | ៥៥ |
| ២១. | ការប្រព្រឹត្តិលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ | ៤៨៩[49] | ៥ | ២០ | ៣២ |

[49] សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការប្រព្រឹត្តិលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ ត្រូវបានបញ្ចូលនៅក្នុងកថាខណ្ឌតែមួយ (កថាខណ្ឌ ៣៥២១)។ ទោះជាយ៉ាងណាក្តី ជើងទំព័រ ១១៨៤១ យោងទៅលើផ្នែកទាំងមូលនៃសាលក្រម៖ "ផ្នែក ១០.១៖ សហករណ៍ត្រាំកក់ ផ្នែក ១១.២៖ ការដ្ឋានការងារទំនប់ ១ មករា ផ្នែក ១២.២៖ មន្ទីរសន្តិសុខ ស-២១ ផ្នែក ១២.៣៖ មន្ទីរសន្តិសុខក្រាំងតាចាន់។ សូមមើលផងដែរ ផ្នែក ១៦.៤.៣.៤៖ គោលបំណងរួម៖ ការកំណត់គោលដៅទៅលើក្រុមជាក់លាក់៖ អតីតអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ"។ តួលេខនៃចំនួន ៤៨៩ ទំព័រ គឺជាចំនួនសរុបនៃទំព័រទាំងអស់ដែលបានយោងទៅជើងទំព័រនេះ ព្រមទាំងចំនួនទំព័រដែលពាក់ព័ន្ធដោយផ្ទាល់នៅក្នុងផ្នែក ១៩៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា។

| | | | | | |
|---|---|---|---|---|---|
| ២២. | បទបញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ | ៩៥ | ២ | ៣៨ | ៥៣ |

៣៨. ដូចបានបង្ហាញនៅក្នុងតារាងខាងលើ ការកំណត់ចំនួន ១.០០០ ទំព័រ មិនត្រឹមតែមានភាពសមហេតុសមផលប៉ុណ្ណោះទេ តែក៏នឹងតម្រូវឱ្យមេធាវីការពារក្តីត្រូវចំណាយថាមពល និងធនធានជាច្រើនបន្ថែមទៀត ក្នុងការរៀបចំសារណាដែលស៊ីចង្វាក់គ្នាជាខ្លាំង។ ដើម្បីផ្តល់នូវឧទាហរណ៍រឹងមាំមួយ តាមរយៈការបង្ហាញនូវការប្រឈមនេះ សាលក្រមបានចំណាយដល់ទៅចំនួន ១៦៦ ទំព័រ ដល់ការដ្ឋានការងារទំនប់ ១ មករា ដែលអង្គជំនុំជម្រះបានសន្និដ្ឋានថាលោក នួន ជា មានពិរុទ្ធភាពចំពោះបទល្មើសចំនួនប្រាំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ មេធាវីការពារក្តីនឹងបង្កើតនូវមូលដ្ឋានចំនួន ៥២ នៃបណ្តឹងសាទុក្ខដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនេះនៅក្នុងផ្នែកដែលមានត្រឹមតែចំនួន ៣៨ ទំព័រ ដែលមូលដ្ឋានមួយនៃបណ្តឹងសាទុក្ខត្រូវចំណាយចំនួន ០,៧ ទំព័រ។

៣៩. ការអនុញ្ញាតតិចជាង ១.០០០ ទំព័រនឹងបង្កើនហានិភ័យដែលបង្ខំដល់មេធាវីការពារក្តីដើម្បីទម្លាក់ចោលមូលដ្ឋានបណ្តឹងសាទុក្ខ ដោយសារតែពុំមានពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ដូចដែលមេធាវីការពារក្តីត្រូវបានបង្ខំឱ្យធ្វើបែបនេះរួចមកហើយក្នុងអំឡុងនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១[50]។ ជាការពិតដែលមិនអាចប្រកែកបានគឺថា មេធាវីការពារក្តីមិនគួរត្រូវបានបង្ខំឱ្យជ្រើសរើសរវាងមូលដ្ឋាននៃបណ្តឹងសាទុក្ខ និងទឡ្ហីករណ៍សំខាន់ៗក្នុងការគាំទ្រដល់បណ្តឹងសាទុក្ខ ដោយសារការកំណត់ចំនួនទំព័រនោះទេ។

## ខ. បញ្ហានានានៅក្នុងបណ្តឹងសាទុក្ខជាបញ្ហាថ្មីប្លែក និងស្មុគស្មាញ

៤០. សំណុំរឿង ០០២/០២ បានបង្កើតបញ្ហាផ្នែកអង្គច្បាប់ថ្មីៗជាច្រើនដែលមិនត្រូវបានយកមកដោះស្រាយពីមុនមក ដោយតុលាការ ឬសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ មិនត្រឹមតែនៅ អ.វ.ត.ក ប៉ុណ្ណោះទេ។ ចំណុចទាំងនេះរួមមាន តែមិនកម្រិតត្រឹម៖

---

[50] ឯកសារ F13 "សំណើបន្ទាន់ សុំការពិចារណាឡើងវិញលើចំនួនទំព័រកំណត់លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ២។

- មូលដ្ឋានដែលមានការរើសអើងចំពោះការវាយប្រហារដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
- និយមន័យនៃពាក្យ “ប្រជាជនស៊ីវិល” សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រជាជនមួយផ្នែកធំនៅតំបន់មួយគឺជាសមាជិកកងកម្លាំងប្រដាប់អាវុធ
- អំពើជាមូលដ្ឋានដែលបានបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងឆ្នាំ១៩៧៥
- ភាពអាចយកមកអនុវត្តបាន និងភាពអាចប្រមើលមើលបាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតដោយមានចេតនាប្រយោលនៅឆ្នាំ១៩៧៥
- ផលប៉ះពាល់នៃស្ថានភាពបន្ទាន់ស្តីពីការកំណត់ជាបទល្មើសចំពោះឧក្រិដ្ឋកម្មមួយចំនួនដែលលោក នួន ជា ត្រូវបានផ្តន្ទាទោស
- ភាពស្របច្បាប់នៃការកំណត់ជាបទល្មើសឡើងវិញនូវអង្គហេតុនានាក្នុងដំណាក់កាលពិភាក្សាដើម្បីចេញសេចក្តីសម្រេច ដោយមិនបានជូនដំណឹងជាមុនដល់ជនជាប់ចោទ និង
- និយមន័យនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។

៤១. ទាំងនេះជាបញ្ហាស្មុគស្មាញដែលតម្រូវឲ្យមានពេលវេលា និងចំនួនទំព័រជាច្រើន ប្រសិនបើបញ្ហាទាំងនេះពិតជាត្រូវបានយកមកដោះស្រាយយ៉ាងស៊ីជម្រៅមែននោះ។ ការបន្ថែមពេលវេលា និងចំនួនទំព័រទៅតាមការស្នើសុំ នឹងអនុញ្ញាតឲ្យមេធាវីការពារក្តីអាចធ្វើបែបនោះបាន គឺថា ដើម្បីដាក់ជូនអង្គជំនុំជម្រះនូវព័ត៌មានទាំងអស់ដែលពាក់ព័ន្ធ ដើម្បីឲ្យអង្គជំនុំជម្រះចេញសេចក្តីសម្រេចរបស់ខ្លួនទៅលើបញ្ហាពិសេសៗ និងសំខាន់ៗទាំងនេះ។

## គ. បទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខដែលតម្រូវឲ្យលើកឡើងនូវទឡ្ហីករណ៍យ៉ាងទូលំទូលាយ

៤២. បទដ្ឋានសម្រាប់ការពិនិត្យលើបណ្តឹងសាទុក្ខនៅ អ.វ.ត.ក តម្រូវឲ្យលើកឡើងនូវទឡ្ហីករណ៍យ៉ាងទូលំទូលាយ។ ដូចដែលអង្គជំនុំជម្រះបានពន្យល់នៅក្នុងសាលដីកាលើសំណុំរឿង ឌុច ថា៖

នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា មានកំហុសអង្គច្បាប់នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដែលកើតចេញពីការភ័ន្តច្រឡំក្នុងការអនុវត្តនូវបទដ្ឋានផ្លូវច្បាប់នោះ អង្គជំនុំជម្រះតុលាការកំពូលនឹងត្រូវកំណត់នូវបទដ្ឋានផ្លូវច្បាប់ដ៏ត្រឹមត្រូវមួយហើយត្រូវពិនិត្យឡើងវិញ នូវផ្នែកសំអាងហេតុដែលពាក់ព័ន្ធរបស់អង្គជំនុំជម្រះសាលាដំបូង។ ការធ្វើបែបនេះ អង្គជំនុំជម្រះតុលាការកំពូលមិនត្រឹមតែកែតម្រូវកំហុសអង្គច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអនុវត្តនូវបទដ្ឋានផ្លូវច្បាប់ដោយត្រឹមត្រូវចំពោះភស្តុតាងដែលមាន នៅក្នុងកំណត់ហេតុនៃការជំនុំជម្រះ ហើយក្នុងករណីចាំបាច់ត្រូវកំណត់ ថាតើខ្លួនជឿជាក់លើបទដ្ឋានពាក់ព័ន្ធនៃការបង្ហាញភស្តុតាងទាក់ទងទៅនឹងសំអាងហេតុ ដែលត្រូវបានជំទាស់ដោយភាគីណាមួយនៅមុនពេល ដែលសំអាងហេតុនេះត្រូវបានទទួលយកនៅក្នុងដំណាក់កាលបណ្តឹងសាទុក្ខដែរ ឬយ៉ាងណា[51]។

៤៣. លក្ខណៈវិនិច្ឆ័យនេះមានន័យថា ភាគីប្តឹងសាទុក្ខត្រូវតែអាចបង្កើតជាមូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដើម្បីជួយអង្គជំនុំជម្រះក្នុងការពិនិត្យលើបណ្តឹងសាទុក្ខ។ កាតព្វកិច្ចនេះកាន់តែធំធេង នៅពេលពាក់ព័ន្ធនឹងកំហុសលើអង្គច្បាប់និងអង្គហេតុចម្រុះគ្នា ដោយសារប្រការទាំងនេះតម្រូវឲ្យមានការពន្យល់ពីសេចក្តីសន្និដ្ឋានអង្គច្បាប់ដែលមានកំហុសឆ្គង ផលប៉ះពាល់របស់វាទៅលើសេចក្តីសន្និដ្ឋានអង្គហេតុជាច្រើន និងតាមវិធីដែលទទួលបានលទ្ធផលផ្សេងពីនេះ ប្រសិនបើយកបទដ្ឋានផ្លូវច្បាប់ត្រឹមត្រូវមកអនុវត្ត។ ដោយហេតុថា មូលដ្ឋានភាគច្រើននៃបណ្តឹងសាទុក្ខដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងរបស់លោក នួន ជា ជាកំហុសចម្រុះគ្នានោះ មេធាវីការពារក្តីនឹងត្រូវការពេលវេលា និងចំនួនទំព័របន្ថែមទៀតដើម្បីរៀបចំការការពារក្តីរបស់ខ្លួន។

៤៤. នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ ក្រោយតែពីពេលធ្វើការវិភាគលើអង្គហេតុយ៉ាងប្រុងប្រយ័ត្នប៉ុណ្ណោះ ទើបអង្គជំនុំជម្រះអាចធ្វើការលើកលែងការចោទប្រកាន់មួយចំនួន[52]។

---

[51] *សំណុំរឿង ០០១* ឯកសារ **F28** "សាលដីកា" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ១៦ (គូសបញ្ជាក់បន្ថែម)។

[52] ឯកសារ **F36** សារណាបណ្តឹងសាទុក្ខរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៣៧, ៦៣១ និង ៧០៤។

ស្រដៀងគ្នាដែរ អង្គជំនុំជម្រះត្រូវចំណាយពេលស្តាប់សក្ខីកម្មពេញមួយថ្ងៃទើបអាចកំណត់ថាតើ សាក្សី សំ សិទ្ធី ដែលបានផ្តល់សក្ខីកម្មជាចម្បងអំពីព្រឹត្តិការណ៍ជាក់លាក់មួយ "ពុំអាចជឿជាក់ និងទុកចិត្តបាន"[53]។ ឧទាហរណ៍ទាំងនេះបង្ហាញថា ដើម្បីលើកឡើងនូវទឡ្ហីករណ៍ដែលអាចទទួលយកបាន និងបំពេញទៅតាមបទដ្ឋាននៃការពិនិត្យលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះ មេធាវីការពារក្តីត្រូវការពេលវេលា និងចំនួនទំព័របន្ថែមយ៉ាងច្រើនលើសពីការកំណត់ពេលវេលា និងចំនួនទំព័រនៅក្នុងច្បាប់ ដើម្បីលើកឡើងនូវការការពារក្តីនៅក្នុងបណ្តឹងសាទុក្ខយ៉ាងមានប្រសិទ្ធភាព។

## <u>ឃ. ការបន្ថែមពេលវេលា និងចំនួនទំព័រដែលបានស្នើសុំស្របទៅនឹងការអនុវត្តន៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត</u>

៤៥. ភាគីវិវាទនៅក្នុងសំណុំរឿងប្រហាក់ប្រហែលគ្នានៅតុលាការ ICTY ក៏បានទទួលពេលវេលាយ៉ាងច្រើនដែរ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន។ ឧទាហរណ៍ មេធាវីនៅក្នុង *រឿងក្តី Karadžić* និង *រឿងក្តី Mladić* បានទទួលរយៈពេលជាងប្រាំបីខែ ដើម្បីដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ក្រោយពេលចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[54]។ ចុងចោទនៅក្នុង *រឿងក្តី Prlić និងអ្នកផ្សេងទៀត* មានរយៈពេលជាងប្រាំពីរខែ ចាប់ពីពេលចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន[55]។

៤៦. អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានផ្តល់ពេលវេលា និងចំនួនទំព័របន្ថែមចំនួនពីរដងទៅលើពេលវេលា និងចំនួនទំព័រដែលបានកំណត់ក្នុងច្បាប់ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ[56]។ ដោយហេតុថា រហូតដល់ខែកក្កដា ឆ្នាំ២០១៧ សេចក្តីជូនដំណឹងគ្រាន់តែជា

---

[53] ឯកសារ **F36** សារណាបណ្តឹងសាទុក្ខរបស់ នួន ជា នៅក្នុងសំណុំរឿង ០០២/០១ កថាខណ្ឌ ៥៣៧, ៦៣១ និង ៧០៤។

[54] សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង *រឿងក្តី Karadžić* ទំព័រ ៣ និង សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ក្នុង *រឿងក្តី Mladić* ទំព័រ ៤។

[55] សេចក្តីសម្រេចលើការបន្ថែមពេលវេលា និងចំនួនពាក្យកំណត់ក្នុង *រឿងក្តី Prlić* ទំព័រ ៤។

[56] សូមមើល *ឧទាហរណ៍* សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង *រឿងក្តី Bemba និងអ្នកផ្សេងទៀត* កថាខណ្ឌ ១៨។ សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង *រឿងក្តី Bemba* កថាខណ្ឌ ៨។ សេចក្តីសម្រេចលើការបន្ថែមទំព័រ

ការប្រកាសពីចេតនារបស់ភាគីក្នុងការបណ្តឹងសាទុក្ខនោះ ក្រុមមេធាវីការពារក្តីនៅតុលាការ ICC អាចចាប់ផ្តើមធ្វើការទៅលើសារណាបណ្តឹងសាទុក្ខរបស់ខ្លួន ចាប់តាំងពីពេលចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងម្ល៉េះ[57]។ ផ្ទុយទៅវិញ ភាគីនៅ អ.វ.ត.ក ដំបូងត្រូវរៀបចំផែនទីបង្ហាញផ្លូវលម្អិតមួយនៃបណ្តឹងសាទុក្ខរបស់ខ្លួន ជាទម្រង់នៃសេចក្តីជូនដំណឹង ហើយនៅក្រោយពេលដែលដាក់សេចក្តីជូនដំណឹងនេះប៉ុណ្ណោះ ទើបភាគីអាចចាប់ផ្តើមធ្វើការលើអង្គសេចក្តីអំពីសារណាបណ្តឹងសាទុក្ខរបស់ខ្លួន។

៤៧. ប្រការសំខាន់គឺថា សំណុំរឿងទាំងអស់នៅចំពោះតុលាការ និងសាលាជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតបានដោះស្រាយ**បញ្ហាអង្គសេចក្តីតិចតួច** នៅពេលប្រៀបធៀបទៅនឹងវិសាលភាពភូមិសាស្ត្រ និងពេលវេលានៃសំណុំរឿង ០០២/០២។ ឧទាហរណ៍ ជនជាប់ចោទ Karadžić និង Mladić ដែលម្នាក់ៗត្រូវបានផ្តន្ទាទោសទៅលើការចោទប្រកាន់ចំនួន ១០ ចំពោះឧក្រិដ្ឋកម្មអន្តរជាតិ នៅតាមទីក្រុងដែលបានជ្រើសរើសនៅក្នុងប្រទេសស៊ែប និង បូស្នី និងហ៊ឺហ្សេហ្គោវីន។ *រឿងក្តី Lubanga* ដែលចុងចោទមានរយៈពេលជាងប្រាំបីខែដើម្បីដាក់សារណាបណ្តឹងសាទុក្ខ[58] ពាក់ព័ន្ធនឹងការផ្តន្ទាទោសតែមួយប៉ុណ្ណោះ[59]។ នៅក្នុង*រឿងក្តី Katanga* មេធាវីការពារក្តីបានទទួលការអនុញ្ញាតចំនួនប្រាំមួយខែដើម្បីដាក់សារណាបណ្តឹង

---

កំណត់ក្នុង*រឿងក្តី Bemba* កថាខណ្ឌ ១៣។ សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង*រឿងក្តី Katanga* កថាខណ្ឌ ២១។

[57] នៅក្នុងសំណោបច្ចុប្បន្នរបស់ខ្លួន បទប្បញ្ញត្តិលេខ ៥៧ នៃបទប្បញ្ញត្តិនៃតុលាការ ICC (ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ហើយចូលជាធរមាននៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៧) តម្រូវឲ្យសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខត្រូវលើកឡើងនូវ "មូលដ្ឋាននៃបណ្តឹងសាទុក្ខ ទោះបីរួមបញ្ចូលគ្នា ឬផ្សេងគ្នា ដោយបញ្ជាក់ច្បាស់ពីកំហុសដែលបានចោទប្រកាន់ និងរបៀបដែលកំហុសទាំងនោះមានឥទ្ធិពលទៅលើសេចក្តីសម្រេចដែលត្រូវបានប្តឹងសាទុក្ខ"។ ទោះជាយ៉ាងណាក្តី លក្ខខណ្ឌតម្រូវនេះពុំមាន នៅពេលដែលច្បាប់យុត្តិសាស្ត្រនេះត្រូវបានដកស្រង់ខាងលើទេ។

[58] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-3121-Red "សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងការផ្តន្ទាទោសរបស់គាត់" ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ៨-៩។

[59] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Lubanga* សំណុំរឿងលេខ ICC-01/04-01/06-2842 "សាលដីកាអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១២ កថាខណ្ឌ ១៣៥៨។

សាទុក្ខរបស់ខ្លួន[60] ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលដោះស្រាយចំពោះបទចោទចំនួនបួន នៅក្រោមទម្រង់នៃការទទួលខុសត្រូវតែមួយ ដែលបទចោទទាំងអស់ពាក់ព័ន្ធនឹងការវាយប្រហារតែមួយដែលបានកើតឡើងតែមួយថ្ងៃ[61]។ ស្រដៀងគ្នាដែរ *រឿងក្តី Bemba* ពាក់ព័ន្ធនឹងបទចោទចំនួនប្រាំនៅក្រោមទម្រង់នៃការទទួលខុសត្រូវតែមួយ[62] ហើយមេធាវីការពារក្តីបានទទួលការអនុញ្ញាតឲ្យដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ក្នុងរយៈពេលប្រាំមួយខែ ចាប់ពីថ្ងៃជូនដំណឹងពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង[63]។

៤៨. បើតាមការប្រៀបធៀប សំណុំរឿងប្រឆាំងលោក នួន ជា ពាក់ព័ន្ធនឹងបទល្មើសចំនួន ២២ នៃឧក្រិដ្ឋកម្មអន្តរជាតិ (ការផ្តន្ទាទោសសរុបចំនួន ៧៨ ជាមួយនឹងការរាប់ដាច់ដោយឡែកចំនួនជិត ៣០០) និងអំពើព្រហ្មទណ្ឌជាច្រើនទៀតដែលត្រូវបានប្រព្រឹត្តនៅទូទាំងទឹកដីនៃប្រទេសកម្ពុជាអស់រយៈកាលជិតបួនឆ្នាំ។ វិសាលភាពនៃសំណុំរឿង ០០២/០២ ដែលមានភាពស្រពិចស្រពិល និងធំធេងជាងសំណុំរឿងស្រដៀងគ្នាជាច្រើននៅឯយន្តការនៃតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ហេតុនេះមេធាវីការពារក្តីគួរទទួលបានពេលវេលា និងចំនួនទំព័រជាច្រើនទៀតដើម្បីរៀបចំសារណាបណ្តឹងសាទុក្ខរបស់ នួន ជា។

## III. សំណើសុំដាក់តែមួយភាសាសិន

៤៩. ចុងក្រោយ មេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យដាក់សារណាបណ្តឹងសាទុក្ខតែមួយភាសាសិន នៅត្រឹមថ្ងៃកំណត់ចុងក្រោយ ចំណែកសំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយនៅពេលបញ្ចប់ការបកប្រែភ្លាម។ ដូចដែលមេធាវីការពារក្តីធ្លាប់បានលើកជាទឡ្ហីករណ៍ពីមុនមកថា លក្ខខណ្ឌតម្រូវនៃការដាក់ជាពីរភាសាផ្លូវការ គឺជាលក្ខណៈពិសេសចំពោះ

---

[60] សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង *រឿងក្តី Katanga* កថាខណ្ឌ ២១។

[61] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Katanga* សំណុំរឿងលេខ ICC-01/04-01/07-3436-tENG "សាលដីកាអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ" ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៤។

[62] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Bemba* សំណុំរឿងលេខ ICC-01/05-01/08-3343 "សាលដីកាអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ" ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦។

[63] សេចក្តីសម្រេចលើការបន្ថែមពេលវេលាកំណត់ក្នុង *រឿងក្តី Bemba* កថាខណ្ឌ ៨។

អ.វ.ត.ក ដែលបណ្តាលឲ្យកាត់បន្ថយពេលវេលាកំណត់ថែមទៀត ដោយសារតែយកឯកសារទៅបកប្រែជាមុនសិន មុននឹងដាក់[64]។ ការដាក់តែមួយភាសាសិនគឺជាដំណោះស្រាយតែមួយគត់ដែលមានភាពយុត្តិធម៌ ដែលធានាថា មេធាវីការពារក្តីមានពេលវេលាគ្រប់គ្រាន់ក្នុងការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ទន្ទឹមនឹងនោះក៏រក្សាបាននូវភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីផងដែរ។

៥០. ផ្អែកលើអត្រានៃការបកប្រែភាសាដែលអង្គភាពបកប្រែភាសាផ្តល់ឲ្យ មេធាវីការពារក្តីប៉ាន់ស្មានថា ក្នុងឯកសារ ១០០ ទំព័រនឹងត្រូវចំណាយពេលដល់ទៅ ២០ ថ្ងៃនៃថ្ងៃធ្វើការ (គឺ បួនសប្តាហ៍) សម្រាប់ការបកប្រែភាសា។ សម្រាប់សារណាដែលមានចំនួន ១.០០០ ទំព័រ អង្គភាពបកប្រែភាសានឹងត្រូវចំណាយពេលដល់ទៅ ១០ ខែ ដោយត្រូវធ្វើការពេញម៉ោង។ ជាងនេះទៀត ដោយសារជារឿយៗ អង្គភាពបកប្រែភាសាធ្វើការចាត់តាំងបុគ្គលិកច្រើននាក់ឲ្យធ្វើការបកប្រែទៅលើឯកសារតែមួយដែលមានទំហំធំធេងបែបនេះ អង្គភាពនេះក៏ត្រូវការពេលវេលាបន្ថែមទៀតដែរ ដើម្បីដាក់បញ្ចូលគ្នា ធ្វើឲ្យមានភាពស៊ីសង្វាក់គ្នា និងកែសម្រួលទៅលើការបកប្រែដែលបានបញ្ចប់។ ការពិត មេធាវីការពារក្តីនឹងខិតខំប្រឹងប្រែងផ្ញើផ្នែកនៃសារណាដែលបានបញ្ចប់ទៅអង្គភាពបកប្រែភាសាជាបន្តបន្ទាប់ ដើម្បីកាត់បន្ថយការពន្យារពេលក្នុងការដាក់សំណៅជាភាសាខ្មែរ។ ទោះជាយ៉ាងណាក្តី ដូចដែលអង្គជំនុំជម្រះជ្រាបស្រាប់ អង្គភាពបកប្រែភាសាផ្តល់សេវាដល់ផ្នែកជាច្រើននៅតុលាការ ហើយមិនអាចធានាបាននូវដំណើរការបកប្រែចំពោះសារណាបណ្តឹងសាទុក្ខទេ។ ទោះបីអង្គជំនុំជម្រះបែងចែកពេលវេលាបែបណាក៏ដោយ តែពេលវេលាមួយផ្នែកធំនឹងត្រូវចំណាយទៅលើការបកប្រែភាសាមិនខាន។

៥១. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះបានទទួលស្គាល់នូវបញ្ហានេះ ហើយបានអនុញ្ញាតឲ្យភាគីដាក់សារណាបណ្តឹងសាទុក្ខជាភាសាអង់គ្លេស ឬភាសាបារាំងជាមុនសិន ចំណែក

[64] ឯកសារ F3 "សំណើបន្ទាន់របស់មេធាវីការពារក្តីលោក ខៀវ សំផន និងមេធាវីការពារក្តីលោក នួន ជា សុំពន្យារពេលកំណត់ និងបង្កើនចំនួនទំព័រនៃបណ្តឹងសាទុក្ខ" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១៩។

សំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ[65]។ មេធាវីការពារក្ដីស្នើសុំឲ្យអនុវត្តវិធីសាស្ត្រដូចគ្នាចំពោះសំណុំរឿងនេះដែរ គឺថា អនុញ្ញាតឲ្យដាក់សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា តែមួយភាសាសិន ចំណែកសំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ។

## ផ្នែកទី ៥. សេចក្ដីសន្និដ្ឋាន

៥២. ដោយសារវិសាលភាព និងភាពស្មុគស្មាញនៃបញ្ហានានាដែលបានកើតឡើងនៅក្នុងសាលក្រម និងដើម្បីធ្វើឲ្យសិទ្ធិរបស់លោក នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌មានប្រសិទ្ធភាពនោះ មេធាវីការពារក្ដីត្រូវការនូវការបន្ថែមពេលវេលាយ៉ាងសមរម្យ រយៈពេល ៨,៥ ខែ (រយៈពេលសរុប ១០,៥ ខែ ចាប់ពីពេលដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ) និងការបន្ថែមទំព័រចំនួន ៩៧០ (សរុបចំនួន ១.០០០ ទំព័រ) សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខរបស់ នួន ជា។ ប្រសិនបើអង្គជំនុំជម្រះសម្រេចផ្ដល់ពេលវេលា និងចំនួនទំព័រតិចជាងនេះ មេធាវីការពារក្ដីត្រូវបង្ខំចិត្តពិចារណាស្នើសុំធនធានបន្ថែមដើម្បីឲ្យទាន់ថ្ងៃកំណត់ចុងក្រោយ សម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ។

## ផ្នែកទី ៦. សំណើសុំ

៥៣. អនុលោមតាមសំអាងហេតុនានាខាងលើ មេធាវីការពារក្ដីស្នើសុំដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

(ក) អនុញ្ញាតជាបន្ទាន់៖

(i) បន្ថែមពេលវេលា ៨,៥ ខែ ដោយពេលវេលាសរុបទាំងអស់មានចំនួន **១០,៥ ខែ** គិតចាប់ពីពេលដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ និង

(ii) បន្ថែមទំព័រចំនួន ៩៧០ ទំព័រ ដោយចំនួនសរុបមាន **១.០០០** ទំព័រ ជាភាសាអង់គ្លេស

ដើម្បីឲ្យមេធាវីការពារក្ដីអាចរៀបចំសារណាបណ្ដឹងសាទុក្ខ នួន ជា បាន និង

---

[65] ឯកសារ **F9** សេចក្ដីសម្រេចលើកទីពីរលើការបន្ថែមពេលវេលា និងចំនួនទំព័រកំណត់ កថាខណ្ឌ ១៩។

(ខ) បង្គាប់ឲ្យដាក់សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីជាភាសាអង់គ្លេសត្រឹមថ្ងៃកំណត់ចុងក្រោយ ចំណែកសំណៅជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយនៅពេលបញ្ចប់ការបកប្រែភ្លាម។

**សហមេធាវីការពារក្ដីលោក នួន ជា**

**សុន អរុណ** **លីវ សុវណ្ណា** **Doreen CHEN**